# អាជ្ញាធរអគ្គិសនីកម្ពុជា

# ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

## ELECTRICITY LAW OF THE KINGDOM OF CAMBODIA

**សេចក្តីសម្រេចកែសម្រួលលើកទី៧**

**លើឯកសារអាជ្ញាប័ណ្ណរួម លេខ ០២០ ឯអ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២**

**សម្រាប់លោក ឈូ ឡៃ**

**ធ្វើសេវាកម្មអគ្គិសនីនៅទីរួមស្រុកព្រៃកប្បាស និងស្រុកបាទី ខេត្តតាកែវ**

**សម្រាប់ការពង្រីកតំបន់ចែកចាយ**

**DECISION ON THE SEVENTH REVISION**
**OF THE CONSOLIDATED LICENSE DOCUMENT No. 020 LD**
**DATED DECEMBER 30, 2002 FOR MR. CHHOU LAY**
**FOR PROVIDING ELECTRICITY SERVICES AT PREY KABAS DISTRICT TOWN**
**AND BATY DISTRICT, TAKEO PROVINCE**
**FOR EXTENDING DISTRIBUTION AREA**

**ថ្ងៃទី... ខែ... ឆ្នាំ២០០៩**

..., 2009

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

លេខ : -០៩-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៧

# លើឯកសារអាជ្ញាប័ណ្ណលេខ ០២០ ឯអ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២

# សម្រាប់លោក ឈូ ឡៃ

## DECISION ON THE SEVENTH REVISION

## TO THE LICENSE DOCUMENT N° 020 LD DATED DECEMBER 30, 2002

## FOR MR. CHHOU LAY

## អាជ្ញាធរអគ្គិសនីកម្ពុជា

## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 2 February 2001.

-យោងឯកសារអាជ្ញាប័ណ្ណរួមរបស់លោក ឈូ ឡៃ លេខ០២០ ឯអ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២

-Refer to the Consolidated License Document of Mrs. Chhou Lay No.020 LD dated December 30, 2002.

-លិខិតស្នើសុំពង្រីកតំបន់ចែកចាយអគ្គិសនីរបស់លោក ឈូ ឡៃ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩

-In accordance with the application for extending distribution area of Mr. Chhou Lay, dated July 13, 2009.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០០៩ ដល់ថ្ងៃទី... ខែ... ឆ្នាំ២០០៩

-In accordance with the consultation with concerned parties and public, made from ..., 2009 to ..., 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី... នៅថ្ងៃទី... ខែ... ឆ្នាំ២០០៩

-In accordance with the decision of Electricity Authority of Cambodia’s Session N°... dated ..., 2009.

# សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលអាជ្ញាប័ណ្ណលេខ ០២០ អ ដែលបានផ្តល់ឱ្យលោក **ឈូ ឡៃ** ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅទីរួមស្រុកព្រៃកប្បាស និងស្រុកបាទី ខេត្តតាកែវ ដោយអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនី ដែលមានស្រាប់ ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុង ឧបសម្ព័ន្ធ១ កែសម្រួលថ្មី ។ | **Article 1**<br>To revise License N° 020 L granted to Mr. Chhou Lay to supply electric power at Prey Kabas District Town and Baty District, Takeo Province to give the right to licensee to extend the existing distribution area as show in the attached map in new revised schedule 1. |
| **ប្រការ ២**<br>ឧបសម្ព័ន្ធទី១ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ០២០ ឯអ ត្រូវជំនួសដោយ ឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The Schedule 1 of the license documents Nº 020 LD shall be replaced by new Schedule1 attached here with. |
| **ប្រការ ៣**<br>សេចក្តីសម្រេច និងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០២០ ឯអ។ | **Article 3**<br>This decision and the attached revised Schedule shall be considered as a part of the license documents Nº 020 LD. |
| **ប្រការ ៤**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃនៃឯកសារអាជ្ញាប័ណ្ណលេខ០២០ ឯអ ត្រូវស្ថិតនៅ ជាធរមានដដែល។ | **Article 4**<br>The other contents and conditions of the license document N° 020 LD shall remain in force. |
| **ប្រការ ៥**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០២០ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ០២០ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មី ស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document Nº 020 LD has been deposited in order that the deposited license document Nº 020 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០០៩

Phnom Penh, ..., 2009

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF EAC

# ឧបសម្ព័ន្ធទី១
# តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
# ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី... នាថ្ងៃទី... ខែ... ឆ្នាំ២០០៩

# SCHEDULE 1

## AUTHORIZED DISTRIBUTION AREAS

## AS AMMENDED IN SESSION OF EAC N°... DATED ..., 2009

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យលោក ឈូ ឡៃ ធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺ ទីប្រជុំជនស្រុកព្រៃកប្បាស និងស្រុកបាទី ខេត្តតាកែវ ។ | 1. The authorized distribution Areas, where Mr. Chhou Lay has the right to provide the electricity distribution and supply services at Prey Kabas District Town and Baty District, Takeo Province. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី កំណត់ដោយផែនទីកំណត់ព្រំប្រទល់ 020 LD-map-Chhou Lay-Revision7-2009 ដែលភ្ជាប់មកជាមួយ ។ | 2. The authorized distribution Areas is determined by the boundary map 020 LD-map-Chhou Lay-Revision7-2009 attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើលោក ឈូ ឡៃ មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀតពេលនោះលោក ឈូ ឡៃ ត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if Mr. Chhou Lay intends to request the extension or the additional distribution areas then Mr. Chhou Lay shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |